

# កណ្ដុរក្នុងផ្ទះ

Sowmya Rajendran

Tanaya Vyas

letsreadasia.org



នៅក្នុងផ្ទះ មានកណ្ដុរមួយក្បាល។ លោកយាយឃើញវាមុនគេ។ គាត់ស្រែកថា "កណ្ដុរ!" រួចគាត់ក៏លោតឡើងលើសាឡុង។ ខ្ទើយកល់ ក៏ធ្លាក់រាយពេញលើកម្រាលឥដ្ឋ។



ពុកស្រែកសួរថា ”នៅឯណា?” រួច
គាត់ក៏ឡើងទៅលើបង្អួច។ គាត់ទាញ
វាំងននធ្លាក់ចុះក្រោម។ ម៉ែក៏លាន់
ថា”នៅទីនោះ!” ពោលរួច គាត់ក៏ហក់
ឡើងទៅលើតុ ធ្វើធ្លាក់បែកចានអស់។



"ចាប់វាឲ្យបាន!" មិថុនា ក៏ស្រែកប្រាប់ទៅឆ្មា។ ប៉ុន្តែឆ្មា គ្រាន់តែឃើញកណ្ដុរ ក៏រត់គេចទៅពួននៅក្រោមគ្រែបាត់! មិថុនា រត់តាមក្រោយឆ្មា ហើយស្រែកថា "កណ្ដុរ!"



ម៉ែនិយាយដោយក្លាហានថា ”ទុកឲ្យខ្ញុំដេញវាចេញ!” ថារួចម៉ែក៏យកអំបោសមករុកចុះឡើង។ ពុកក៏លាន់មាត់ ”កណ្ដុរ! វានៅក្រោយម៉ែវាឯងហ្នឹង!” ម៉ែឃើញកណ្ដុរ ក៏រត់ទៅពួននៅក្រោមគ្រែ។



លោកយាយ លោតចុះពីសាឡុងហើយស្រែកថា ”យាយដឹងថាត្រូវធ្វើម៉េចហើយ!” គាត់មូរក្រដាសកាសែត ហើយរុកចុះឡើង។



ពុកស្រែកខ្លាំងៗថា ”កណ្ដុរ!” រួច
គាត់តោងឡើងបង្អួចកាន់តែខ្ពស់។
លោកយាយក្រឡេកឃើញកណ្ដុររត់ ក៏
ស្រែកថា ”វាទៅខាងឆ្វេងដៃ” រួចគាត់ក៏
រត់ទៅពួននៅក្រោមគ្រែដែរ។



ពុកពោលតិចៗថា "អូ វីវរហើយ!" គាត់មិនអាចតោងឡើងទៅលើទៀតបានទេ។ គាត់ខំស្រវាចុះពីបង្អួចវិញយ៉ាងប្រុងប្រយ័ត្ន ទៅពួននៅក្រោមគ្រែដែរ ដើម្បីកុំឲ្យកណ្តុររកគាត់ឃើញ។



អ្នកទាំងអស់ក៏ស្រែកព្រមគ្នាថា "កណ្តុរ
នៅក្នុងផ្ទះ!" សំឡេងនេះ ធ្វើឲ្យកូនង៉ែត
ភ្ញាក់ឡើង។ នាងក្រោកអង្គុយលើ
កម្រាល ហើយយកដៃញីភ្នែកទាំង
មមើ។ តើអ្វីនៅលើខ្នើយរបស់នាង?



វាមានភ្នែកពីរ ជើងបួន ហើយកន្ទុយមួយយ៉ាងវែង។ ក្មេងតូច និយាយថា ”កណ្តុរ!” រួចទះដៃយ៉ាងរីករាយ។ ក្មេងតូចនោះ មើលទៅកណ្តុរ។ កណ្តុរក៏រត់គេច ដោយក្មេងតូចដេញតាមវាពីក្រោយ!



កណ្ដុរ ហក់ឡើងលើសាឡុង ឡើងលើ
បង្អួច លោតឡើងលើតុ ដួលដាំដូងលើ
ខ្នើយ...



...វារត់តាមចន្លោះរាំងនន កាត់ពីលើចាន ហើយក៏ចេញប្រូចតាមទ្វារទៅបាត់!

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Mouse in the House, author: Sowmya Rajendran. illustrator: by Tanaya Vyas. Published by Pratham Books, https://storyweaver.org.in/stories/876-mouse-in-the-house © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Chou Chinith